# សេចក្តីជូនដំណឹង

## ចំពោះនិស្សិតបរទេសដែលកំពុងគិតអំពីការដាក់ពាក្យសុំសិទ្ធិជ្រកកោនជាជនភៀសខ្លួន

ខែកុម្ភៈឆ្នាំ២០១៨

ការិយាល័យអន្តោប្រវេសន៍ក្រសួងយុត្តិធម៌

តាំងពីមុនមក ក្រសួងយុត្តិធម៌បានផ្តល់សិទ្ធិចូលធ្វើការដល់ជនបរទេស ដែលស្នាក់នៅប្រទេសជប៉ុនដោយស្របច្បាប់ ហើយពេលដែលជនបរទេសនេះបានដាក់ពាក្យស្នើសុំសិទ្ធិជ្រកកោនជាជនភៀសខ្លួនបានលើសប្រាំមួយខែហើយ។ ក៏ប៉ុន្តែ នៅថ្ងៃទី១៥ខែមករាឆ្នាំនេះ ក្រសួងបានពិនិត្យនិងកែតម្រូវលក្ខខណ្ឌដូចតទៅនេះ។

ជាទូទៅ ចំពោះនិស្សិតបរទេស បើសិនជាមកដាក់ពាក្យស្នើសុំសិទ្ធិជ្រកកោនជាជនភៀសខ្លួនក្រោយត្រូវបានបញ្ចេញចេញពីស្ថាប័នអប់រំ ឬក៏ក្រោយបញ្ចប់ការសិក្សា ក្រសួងមិនអនុញ្ញាតឲ្យចូលធ្វើការឡើយ ទោះជាលើសប្រាំមួយខែ ក្រោយពីដាក់ពាក្យស្នើសុំសិទ្ធិជ្រកកោនក៏ដោយ។

(ចំណាំ១) អាចដាក់ពាក្យស្នើសុំសិទ្ធិជ្រកកោងជាជនភៀសខ្លួនបាន ក្នុងការបន្តសិក្សា។

(ចំណុចទី២) ក្រសួងនឹងអនុញ្ញាតឲ្យចូលធ្វើការ ក្នុងករណីអាចទទួលស្គាល់ជាជនភៀសខ្លួន

តាមសន្ធិសញ្ញាស្តីពីជនភៀសខ្លួនកំណត់ ឬ ករណីដែលត្រូវការពិចារណាជាលក្ខណ

មនុស្សធម៌ តាមស្ថានភាពនៃប្រទេសកំណើតរបស់អ្នកដាក់ពាក្យស្នើសុំសិទ្ធិជ្រកកោននេះ។

ទន្ទឹមនឹងនេះ នៅស្ថាប័នអប់រំដែលលោកអ្នកកំពុងសិក្សា ពេលណាដែលមានចម្ងល់ថា មានអំពើខុសច្បាប់ សូមអញ្ជើញទាក់ទងទៅការិយាល័យអន្តោប្រវេសន៍ ដែលនៅជិតកន្លែងលោកអ្នកកំពុងរស់នៅដើម្បីពិគ្រោះយោបល។